# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២២ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មការសំរាប់គ្រប់គ្រងថវិកា និងត្រួតពិនិត្យគុណភាពសំណង់អាគារសាកលវិទ្យាល័យបាត់ដំបង

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតសាកលវិទ្យាល័យបាត់ដំបង
- បានឃើញសេចក្តីសំរេចលេខ ១៦ សសរ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់សាកលវិទ្យាល័យបាត់ដំបង
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-** បង្កើតអនុគណៈកម្មការចំនួន២ដូចខាងក្រោម សំរាប់ជាជំនួយការឱ្យគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបង ÷

- អនុគណៈកម្មការគ្រប់គ្រងថវិកា និងសម្ភារៈបរិក្ខារសំណង់
- អនុគណៈកម្មការត្រួតពិនិត្យគុណភាពសំណង់អាគារ ។

www.pheakdeylaw.com

**ប្រការ ២.-** សមាសភាព និងភារកិច្ចនៃអនុគណៈកម្មការនីមួយៗមានដូចខាងក្រោម :

២.១-អនុគណៈកម្មការគ្រប់គ្រងថវិកា និងសម្ភារៈបរិក្ខារសំណង់

ក- សមាសភាព :

| | | |
|---|---|---|
| ១- ឯកឧត្តម ប្រាជ្ញ ចន្ទ | អភិបាលខេត្តបាត់ដំបង | ប្រធាន |
| ២- ឯកឧត្តម អ៊ុយ ស៊ីម | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | អនុប្រធាន |
| ៣- ឯកឧត្តម ខាវ អឿង | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៤- ឯកឧត្តម មាស សារឹម | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | សមាជិក |
| ៥- លោក ឡាយ បូរិន | ប្រធាននាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦- លោក អ៊ុយ លីម | នាយរងខុទ្ទកាល័យសាលាខេត្តបាត់ដំបង | សមាជិក |
| ៧- លោក នុត ម៉ុណ្ណា | នាយក្រុមហិរញ្ញវត្ថុសាលាខេត្តបាត់ដំបង | សមាជិក |
| ៨- លោក ជុក ម៉ិនធឿន | អនុប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តបាត់ដំបង | សមាជិក |
| ៩- លោក អ៊ុយ សុធាវី | នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តបាត់ដំបង | សមាជិក |
| ១០- លោក ខួន គឹមសិន | ប្រធានការិយាល័យចំណូលសាលាខេត្តបាត់ដំបង | សមាជិក |
| ១១- លោក ធឿន ហេង | ប្រធានការិយាល័យគណនេយ្យសាលាខេត្តបាត់ដំបង | សមាជិក |

ខ- ភារកិច្ចរបស់អនុគណៈកម្មការ :

- គ្រប់គ្រងថវិកា និងសម្ភារៈបរិក្ខារសំណង់សម្រាប់បំរើឱ្យការងារសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបង
- គ្រប់គ្រងថវិកាចំណូលមានបញ្ជីឯកសារអោយបានត្រឹមត្រូវច្បាស់លាស់
- រៀបចំបែបបទចំណាយដើម្បីសុំគោលការណ៍ពិនិត្យ និងសម្រេចពីប្រធានគណៈកម្មការសម្រាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបង
- គ្រប់គ្រងបញ្ជីចំណាយ និង ខិតខំត្បិតត្បៀតសន្សំសំចៃចំពោះគម្រោងចំណាយណាដែលពុំចាំបាច់
- គ្រប់គ្រងសម្ភារៈបរិក្ខារសំណង់ ដោយធ្វើការទទួល និងបញ្ចេញបញ្ចូលមានលិខិតស្នាមត្រឹមត្រូវច្បាស់លាស់
- ធ្វើរបាយការណ៍ទៀងទាត់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ រហូតដល់បញ្ចប់គម្រោងសាងសង់អាគារសាកលវិទ្យាល័យជាស្ថាពរ ។

២.២- អនុគណៈកម្មការត្រួតពិនិត្យគុណភាពសំណង់អាគារ

ក- សមាសភាព :

| | | |
|---|---|---|
| ១- ឯកឧត្តម ម៉ម សុផាណា | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | ប្រធាន |
| ២- ឯកឧត្តម អ៊ុយ ស៊ីម | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | អនុប្រធាន |
| ៣- ឯកឧត្តម អ៊ុក ខឿ | អភិបាលរងខេត្តបាត់ដំបង | អនុប្រធាន |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៤- ឯកឧត្តម | ចាន់ ណារ៉ាវ៉េត | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ៥- ឯកឧត្តម | ហ៊ុយ ណារ៉ា | អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- ឯកឧត្តម | ឈុន ភាន់ឌី | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | សមាជិក |
| ៧- លោក | ម៉ត់ ខយ | អគ្គនាយករង នៃអគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨- លោក | អ៊ុយ រី | អភិបាលស្រុកបាត់ដំបង | សមាជិក |
| ៩- លោក | យូ ទីរៈ | អនុប្រធាននាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០- លោក | ខួន វេនេះ | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តបាត់ដំបង | សមាជិក |
| ១១- លោក | ឆៅ ប្រុង | នាយខុទ្ទកាល័យសាលាខេត្តបាត់ដំបង | សមាជិក |
| ១២- លោក | ឌុច ភាន់ឈាន | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង | សមាជិក |
| ១៣- លោក | ម៉ៅ ម៉ើ | ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង | សមាជិក |
| ១៤- លោក | ខាន់ ម៉ារ៉ាណេរ | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបាត់ដំបង | សមាជិក |
| ១៥- លោកឧកញ៉ា | ទ៊ឹក ជួរ | អ្នកទទួលម៉ៅការសាងសង់សាកលវិទ្យាល័យ | សមាជិក |
| ១៦- លោក | សៀង សច់ឯម | ទីប្រឹក្សាអភិបាលខេត្តបាត់ដំបង | សមាជិក |
| ១៧- លោក | ចេង ខ្មែរ | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបាត់ដំបង | សមាជិក |
| ១៨- លោក | ពាង ណារិទ្ធ | អគ្គលេខាធិការសាលាខេត្តបាត់ដំបង | សមាជិក |
| ១៩- លោក | នាង ច័ន្ទថារ៉ា | អគ្គលេខាធិការរងសាលាខេត្តបាត់ដំបង | សមាជិក |
| ២០- លោក | ឈឹម សំណាង | ប្រធានការិយាល័យកិច្ចការសុរិយោដីខេត្តបាត់ដំបង | សមាជិក |

ខ. ភារកិច្ចរបស់អនុគណៈកម្មការ :

- ធ្វើការត្រួតពិនិត្យការងារសាងសង់សំណង់អាគារសាកលវិទ្យាល័យបាត់ដំបង ឱ្យបានសមស្រប តាមបទដ្ឋានបច្ចេកទេសសំណង់ និងគំរោងប្លង់ គ្រឿងបង្គុំសំណង់ ដែលបានសម្រេចជាផ្លូវការរួចហើយ
- ត្រួតពិនិត្យ និងជំរុញឱ្យអនុវត្តតាមប្រតិទិនការងារនៃដំណើរការគម្រោងសាងសង់អាគារ ឱ្យទាន់ពេលវេលា
- ត្រួតពិនិត្យជាប្រចាំលើការងារបច្ចេកទេសនៃការសាងសង់ ដើម្បីធានាឱ្យបាននូវគុណភាពសំណង់រឹងមាំ យូរអង្វែងប្រកបដោយរចនាបថល្អ

www.pheakdeylaw.com

- ករណីពិនិត្យឃើញថាមានភាពមិនប្រក្រតីលើការងារសាងសង់ អនុគណៈកម្មការត្រូវធ្វើការប្រជុំជាបន្ទាន់ដើម្បីមានវិធានការដោះស្រាយ
- ធ្វើរបាយការណ៍អំពីល្បឿននៃការសាងសង់ ជូនគណៈកម្មការសម្រាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបងដើម្បីជូនជ្រាប និងណែនាំបន្ត
- ប្រធានអនុគណៈកម្មការត្រូវកោះប្រជុំអនុប្រធាន និងសមាជិកគណៈកម្មការឱ្យបានជាប្រចាំដើម្បីកំណត់ការទទួលខុសត្រូវក្នុងការអនុវត្តការងាររបស់ខ្លួន ។

**ប្រការ ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង-សាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ព្រមទាំងអភិបាលខេត្តពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៧

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចចែងក្នុងប្រការ ៣
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com